**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ 008 សហវ.ស.ព

# សេចក្ដីណែនាំអនុវត្ត
# អាជ្ញាប័ណ្ណឆ្នោត

អនុលោមតាមសេចក្ដីជូនដំណឹងលេខ ១១២៥ សជណ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃ ទី ០១ ខែ សីហា ឆ្នាំ ២០០២ ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាជូសមុខដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( ក្រសួង) ផ្ដល់អាជ្ញាប័ណ្ណជូន លោក **BENJAMIN JOSEPH PERRY** ជនជាតិអាមេរិកជានាយកក្រុមហ៊ុនហ្គោល ដេន វីន វីន (ខេមបូឌា) អ៊ីន **GOLDEN WIN WIN (CAMBODIA) INC** ដែលមានអាស័យដ្ឋានផ្ទះលេខ ៩ ផ្លូវលេខ ៥៩២ សង្កាត់បឹងកក់ទី ២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីធ្វើអាជីវកម្មឆ្នោតនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមលក្ខខ័ណ្ឌ ដូចខាងក្រោម :

## ប្រការ ១ : ការផ្ដល់អាជ្ញាប័ណ្ណ

អ្នកទទួលអាជ្ញាប័ណ្ណត្រូវបានអនុញ្ញាតអោយធ្វើអាជីវកម្មឆ្នោត នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមលក្ខខ័ណ្ឌដូចមានចែងក្នុងប្រការ២ ហើយត្រូវផ្ដល់និងថែរក្សាប្រព័ន្ធឆ្នោតតាមគុណភាព និងកំរិតអន្តរជាតិ ។ ប្រភេទឆ្នោតដែលអ្នកទទួលអាជ្ញាប័ណ្ណ ត្រូវបានអនុញ្ញាតអោយធ្វើអាជីវកម្ម គឺប្រភេទឆ្នោតកោស និងឆ្នោតឡូតូ ៦/៤៩ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះប្រភេទឆ្នោតដែលបានទទួលការអនុញ្ញាតហើយ តែអ្នកទទួលអាជ្ញាប័ណ្ណមិនបានធ្វើអាជីវកម្ម ឬធ្វើអាជីវកម្មហើយ ប៉ុន្តែបានផ្អាកសកម្មភាពលើស ពីរយៈពេល ០៤ ខែ ប្រភេទឆ្នោតនោះ នឹងត្រូវអស់សុពលភាពដោយស្វ័យប្រវត្តិ ។ មុននឹងធ្វើអាជីវកម្ម អ្នកទទួលអាជ្ញាប័ណ្ណត្រូវផ្ដល់នូវការត្រួតពិនិត្យលើកំរិតបច្ចេកទេស និងទីតាំងនៃការលេងល្បែងឆ្នោតឡូតូពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយបានរយៈពេលមួយខែជាមុនសិន ។ អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវគោរពច្បាប់ឆ្នោតនៃព្រះរាជាណាចក្រកម្ពុជាដែលមានជាធរមាន ហើយនិងបទបញ្ញត្តិ ឬប្រកាសផ្សេងៗទៀត ដែល[illegible] ហើយព្រមទាំងអនុវត្តអោយបានស្របតាមបទបញ្ញត្តិ ឬប្រកាសផ្សេងៗ ដែលដាក់ចេញដោយ[illegible] នីមួយៗដែលទាក់ទងទៅនឹងទំរង់ការ មាតិការ រចនាបទ និងតំលៃនៃសន្លឹកឆ្នោត ។

## ប្រការ ២ : រយៈពេលនៃអាជ្ញាប័ណ្ណ

អាជ្ញាប័ណ្ណនេះត្រូវផ្តល់អោយមានរយៈពេល ៣ឆ្នាំ គិតចាប់តាំងពីថ្ងៃចុះហត្ថលេខាលើអាជ្ញាប័ណ្ណ ។ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណ មានបំណងចង់បន្តរយៈពេលអាជ្ញាប័ណ្ណជាថ្មីទៀត ត្រូវដាក់ពាក្យសុំការអនុញ្ញាតពីក្រសួងមិនអោយលើសពីរយៈពេល ៣ខែ មុនកាលបរិច្ឆេទបញ្ចប់អាជ្ញាប័ណ្ណ ។ ការផ្តល់អោយបន្តអាជ្ញាប័ណ្ណនេះជាថ្មី គឺជាសិទ្ធិរបស់ក្រសួង ។

## ប្រការ ៣ : ប្រាក់ចំណូលដែលត្រូវបង់ជូនរដ្ឋ

អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវបង់ចំណូលចូលរតនាគារជាតិតាមចំនួនភាគរយនៃផលរបរដុល លើការលក់សន្លឹកឆ្នោតតាមអត្រាដូចខាងក្រោម :

| | |
|---|---|
| ឆ្នាំទី ១ ដល់ឆ្នាំទី ៥ | ១០% |
| ឆ្នាំទី ៦ ដល់ឆ្នាំទី ១០ | ១២% |
| ឆ្នាំទី ១១ ដល់ឆ្នាំទី ១៥ | ១៣% |
| ឆ្នាំទី ១៦ ដល់ឆ្នាំទី ២៥ | ១៥% |

ប្រាក់ចំណូលនេះ ត្រូវបង់ចូលរតនាគារជាតិជារៀងរាល់ខែយ៉ាងយូរត្រឹមថ្ងៃទី១០នៃខែបន្ទាប់ ។ ចំពោះប្រាក់ចំណេញដែលក្រុមហ៊ុនទទួលបាន ត្រូវទុកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដើម្បីត្រួតពិនិត្យលើប្រាក់ចំណូលនេះអោយបានត្រឹមត្រូវ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ) និងអ្នកទទួលអាជ្ញាប័ណ្ណ ត្រូវធ្វើការត្រួតពិនិត្យរួមគ្នានូវចំនួនសន្លឹកឆ្នោត ឬ លិខិតយុត្តិការនៃការធ្វើអាជីវកម្មឆ្នោត ឡូតូ (ដែលមានសញ្ញាសំគាល់អនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) មុននឹងដាក់លក់និងសន្លឹកឆ្នោតនៅសល់ ។

## ប្រការ ៤ : ពន្ធអាករផ្សេងៗ

ក្រៅពីការបង់ប្រាក់ចំណូល ដូចមានចែងក្នុងប្រការ៣ អ្នកទទួលអាជ្ញាប័ណ្ណត្រូវបង់ពន្ធអាករផ្សេងៗទៀតទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ ៥ : របាយការណ៍ប្រចាំខែ

អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវថែរក្សាទុកដាក់យ៉ាងហ្មត់ចត់នូវឯកសារផ្សេងៗ ដែលទាក់ទងទៅនឹងការធ្វើអាជីវកម្មឆ្នោត ។ នៅពេលបង់ចំណូលក្នុងខែនីមួយៗ អ្នកទទួលអាជ្ញាប័ណ្ណត្រូវផ្តល់នូវរបាយការណ៍លំអិតបញ្ជាក់ពីប្រាក់ចំណូលដុលដែលបានមកពីការធ្វើអាជីវកម្មឆ្នោតក្នុងខែមុនមកក្រសួងអោយបានមុនថ្ងៃទី ០៥នៃខែបន្ទាប់ ។ របាយការណ៍នេះ ត្រូវបញ្ជាក់ថាជាការពិត និងត្រឹមត្រូវដោយអ្នកតំណាងម្នាក់ដែលអ្នកទទួលអាជ្ញាប័ណ្ណផ្តល់សិទ្ធិ ។

## ប្រការ ៦ : របាយការណ៍ប្រចាំឆ្នាំ

ក្នុងរយៈពេល៣ខែ ក្រោយពីការបញ្ចប់ឆ្នាំនីមួយៗ អ្នកទទួលអាជ្ញាប័ណ្ណត្រូវ[illegible] នេយ្យ

នៃឆ្នាំសារពើពន្ធដែលត្រូវបានត្រួតពិនិត្យ ដោយស្នងការគណនីមកពីក្រុមហ៊ុនត្រួតពិនិត្យគណនេយ្យដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុទទួលស្គាល់ ។ របាយការណ៍របស់ស្នងការគណនីមួយច្បាប់ត្រូវផ្ញើជូនក្រសួង ។

## ប្រការ ៧ : ការត្រួតពិនិត្យបញ្ជី

រយៈពេលប្រាំពីរថ្ងៃ ក្រោយពីការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬក្នុងករណីចាំបាច់ក្រសួងមានសិទ្ធិចុះធ្វើការត្រួតពិនិត្យសៀវភៅបញ្ជីស្ទាម និង ឯកសារផ្សេងៗ ទៀតដែលជាប់ទាក់ទងទៅនឹងការធ្វើអាជីវកម្មឆ្នោត ។ អ្នកទទួលអាជ្ញាប័ណ្ណត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរបស់ក្រសួង ដើម្បីធ្វើការត្រួតពិនិត្យបញ្ជីស្ទាម និង ឯកសារផ្សេងៗ របស់អ្នកទទួលអាជ្ញាប័ណ្ណ ។ ក្រសួងមានសិទ្ធិជួលគណនេយ្យករ ដើម្បីចូលរួមក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ និងមានសិទ្ធិថតចម្លងនូវឯកសារផ្សេងៗ តាមតំរូវការក្នុងការត្រួតពិនិត្យ ។

## ប្រការ ៨ : ការធ្វើអាជីវកម្មឆ្នោត

សន្លឹកឆ្នោតដែលដាក់លក់ដោយអ្នកទទួលអាជ្ញាប័ណ្ណត្រូវ :

ក-ផ្តល់នូវភាពត្រឹមត្រូវយុត្តិធម៌ និងស្មើភាពគ្នាក្នុងការទទួលរង្វាន់ចំពោះអ្នកទិញ ។

ខ-ផ្តល់យ៉ាងតិច ៥០% នៃចំណូលពីការលក់សន្លឹកឆ្នោត សំរាប់ជារង្វាន់ចំពោះអ្នកទិញ ក្រោយពីបានបង់ចំណូលចូលថវិកាដោយផ្អែកតាមអត្រាដែលបានកំណត់ ។

គ-ការចេញឆ្នោត ត្រូវចេញដោយស្ថិតក្រោមការត្រួតពិនិត្យនៃភាគីឯករាជ្យមួយនៃក្រុមហ៊ុនត្រួតពិនិត្យគណនេយ្យដែលមានការទទួលស្គាល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ឃ-លទ្ធផលនៃការចេញឆ្នោត ត្រូវចុះផ្សាយតាមសារពត៌មានណាមួយ ដែលកំពុងផ្សាយពត៌មានទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះសន្លឹកឆ្នោតជ័យលាភីត្រូវបើករង្វាន់ជូន ក្នុងរយៈពេល ៣០ថ្ងៃ និងត្រូវជូនដំណឹងអំពីលទ្ធផលនៃការបើករង្វាន់មកក្រសួង ។

ង-បានអនុវត្តស្របទៅតាមលក្ខខ័ណ្ឌ ដែលនឹងមានចែងក្នុងច្បាប់តាមដំណាក់កាលនីមួយៗ ។

## ប្រការ ៩ : ផ្ញើគណនីនៅរតនាគារជាតិ

អ្នកទទួលអាជ្ញាប័ណ្ណត្រូវតំកល់ប្រាក់រធានារង្វាន់របស់ខ្លួន នៅរតនាគារជាតិដើម្បីប្រើប្រាស់ក្នុងការទិញរង្វាន់ ឬបើកប្រាក់រង្វាន់ដល់ជ័យលាភីនីមួយៗនៅពេលដែលក្រុមហ៊ុនមានបញ្ហាហិរញ្ញវត្ថុមិនអាចដោះស្រាយបាន ឬក្រុមហ៊ុនក្ស័យធន ។ សាច់ប្រាក់ដែលត្រូវតំកល់ទៅរតនាគារជាតិនេះគឺស្មើនឹង ៥០% នៃផលរបរដុលក្រោយពីបានបង់ចំណូលរតនាគារជាតិតាមអត្រាកំណត់ ។

## ប្រការ ១០ : ការផ្ទេរឈ្មោះអ្នកចែកចាយ និងភ្នាក់ងារ

អ្នកទទួលអាជ្ញាប័ណ្ណមិនត្រូវផ្ទេរអាជ្ញាប័ណ្ណនេះ ទៅអោយភាគីណាមួយផ្សេងទៀតដោយគ្មានការឯកភាពជា

ហើយលក្ខណ៍អក្សរពីក្រសួងទេ ។ អ្នកទទួលអាជ្ញាប័ណ្ណមានសិទ្ធិជួលបុគ្គលិក និងបង្កើតដំណើរការបណ្តាញលក់សន្លឹកឆ្នោត នៅក្នុងតំបន់នីមួយៗដែលទទួលបានការអនុញ្ញាត ។

**ប្រការ ១១ : ការផាកពិន័យ**

-អ្នកទទួលអាជ្ញាប័ណ្ណ ខកខានមិនបានបង់ប្រាក់ចំនួនណាមួយ (សារពើពន្ធ ចំណូលរតនាគារជាតិ និងប្រាក់តំកល់ធានារង្វាន់ )ទៅក្រសួងតាមកាលកំណត់ ។ ការបង់ប្រាក់របស់អ្នកទទួលអាជ្ញាប័ណ្ណ ដែលបានធ្វើឡើងក្រោយកាលកំណត់ នឹងត្រូវទទួលការផាកពិន័យដូចមានចែងក្នុងច្បាប់សារពើពន្ធពីមាត្រា ទី ១២៥ ដល់មាត្រា ១៤០ ទៅតាមខ្លឹមសារសង្ខេបដូចខាងក្រោម :

ក.យឺតយ៉ាវ ០១ខែត្រូវពិន័យ១០%បូកការប្រាក់២%លើចំនួនទឹកប្រាក់មិនបានបង់ ឬចំនួនដែលបង់ខ្វះ ។

ខ.យឺតយ៉ាវច្រើនខែត្រូវពិន័យ ២៥% ទៅ ៤០% បូកនឹងការប្រាក់២%លើចំនួនប្រាក់មិនបានបង់ ឬចំនួន ចំនួនដែលបង់ខ្វះ ។

-ចំពោះផលរបរដែលមិនបានប្រកាសមកក្រសួង នឹងត្រូវទទួលការផាកពិន័យ ១០ដង នៃចំនួនដែលមិនប្រកាស ។

-អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវធ្វើលិខិតជូនដំណឹងមកក្រសួងស្តីពីការផ្អាកសកម្មភាពអាជីវកម្មចំនួន ១៥ថ្ងៃ មុនការផ្អាកសកម្មភាព ។ ក្នុងករណីជូនដំណឹងក្រោយការផ្អាកលើសពីចំនួន ០៣ថ្ងៃ ក្រុមហ៊ុនត្រូវរងទទួលការផាកពិន័យស្មើនឹង ១០ដង នៃចំណូលរតនាគារជាតិខែចុងក្រោយដែលបានបង់ហើយ ។

**ប្រការ ១២ : ការបញ្ឈប់សកម្មភាពអាជីវកម្ម**

ក្រសួងមានសិទ្ធបញ្ឈប់សកម្មភាពអាជីវកម្មរបស់អ្នកទទួលអាជ្ញាប័ណ្ណក្នុងករណី :

-អ្នកទទួលអាជ្ញាប័ណ្ណ ធ្វើសកម្មភាពប្រភេទល្បែងដែលគ្មានការអនុញ្ញាតក្នុងអាជ្ញាប័ណ្ណ គ្មានការអនុញ្ញាតបន្ថែមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមានការអនុញ្ញាតហើយ ប៉ុន្តែអនុវត្តខុសពីបទដ្ឋានបច្ចេកទេសដែលក្រសួងបានកំណត់ ។

-អ្នកទទួលអាជ្ញាប័ណ្ណ កំពុងធ្វើសកម្មភាពអាជីវកម្មជាមួយនឹងអាជ្ញាប័ណ្ណដែលអស់សុពលភាព ។ ក្រុមហ៊ុនអាចចាប់ផ្តើមធ្វើសកម្មភាពរបស់ខ្លួនឡើងវិញបន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណថ្មីពីក្រសួង ។

-ចំណូលអាជីវកម្មប្រចាំខែរបស់ក្រុមហ៊ុនមានកំរិតមិនសមស្របនឹងទំហំអាជីវកម្ម ។

**ប្រការ ១៣ : ការលុបចោលអាជ្ញាប័ណ្ណ**

ក្រសួងមានសិទ្ធិលុបចោលអាជ្ញាប័ណ្ណទៅតាមព្រឹត្តិការណ៍ និងដំណោះស្រាយទាំងឡាយ ដែលអ្នកទទួលអាជ្ញាប័ណ្ណពុំបានឆ្លើយតបក្រោយរយៈពេល ១៥ ថ្ងៃ ទៅនឹងសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សររបស់ក្រសួងស្តីពីការផ្តោតទៅលើការមិនគោរព និង មិនអនុវត្តតាមលក្ខខណ្ឌរបស់អាជ្ញាប័ណ្ណដូចខាងក្រោម :

ក-អ្នកទទួលអាជ្ញាប័ណ្ណពុំបានចាប់ផ្តើមបើកធ្វើអាជីវកម្មក្នុងរយៈពេល ០៦ខែ (ប្រាំមួយខែ) គិតចាប់ពីខែដែលបានចេញអាជ្ញាប័ណ្ណ ។ ក្នុងករណីមានមូលហេតុសមស្រប និងច្បាស់លាស់ការពន្យាពេលបើក អាជីវកម្មអាស្រ័យលើការសំរេចរបស់ក្រសួង ។

ខ- អ្នកទទួលអាជ្ញាប័ណ្ណពុំបានអនុវត្តតាមលក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណ ទៅតាមច្បាប់ឆ្នោតនៃព្រះរាជាណាចក្រកម្ពុជា (ច្បាប់ដែលបានអនុម័តរួចនិងវិសោធនកម្មទៅតាមដំណាក់កាលនីមួយៗ) ឬមិនគោរពតាមការណែនាំផ្សេងៗរបស់ក្រសួង ។

គ- អ្នកទទួលអាជ្ញាប័ណ្ណផ្អាកសកម្មភាពអាជីវកម្មលើសពី ០២ខែ ដោយគ្មានមូលហេតុ ។

ឃ-អ្នកទទួលអាជ្ញាប័ណ្ណដំណើរការអាជីវកម្ម ដោយគ្មានតំកល់ប្រាក់ធានាសងរង្វាន់តាមការកំណត់របស់ក្រសួង ។

ង-មានការខុសគ្នាធំដុំណាមួយ រវាងរបាយការណ៍ប្រចាំខែដែលបានដាក់ជូនក្រសួង និងរបាយការណ៍ត្រួតពិនិត្យគណនីដែលបានរៀបចំឡើង ដើម្បីដាក់ជូនក្រសួងនាដំណាច់ឆ្នាំនីមួយៗ ។

ច- អ្នកទទួលអាជ្ញាប័ណ្ណខកខានមិនបានផ្តល់បញ្ជីវិភាគគណនី និងឯកសារផ្សេងៗដែលទាក់ទងនឹងការធ្វើអាជីវកម្មឆ្នោតតាមសេចក្តីត្រូវការរបស់ក្រសួង ។

ឆ- អ្នកទទួលអាជ្ញាប័ណ្ណផ្ទេរកម្មសិទ្ធិអាជ្ញាប័ណ្ណ ទៅអោយអ្នកផ្សេងទៀតដោយពុំមានការអនុញ្ញាត ។

ជ- អ្នកទទួលអាជ្ញាប័ណ្ណក្ស័យធនក្នុងការធ្វើអាជីវកម្ម ក្រសួងនឹងចេញបញ្ជាឱ្យបញ្ឈប់សកម្មភាពធ្វើអាជីវកម្ម និងធ្វើការទូទាត់បំណុល ហើយក្រសួងនឹងចាត់តាំងអ្នកចាត់ចែងការអោយទទួលបន្ទុកជំនួស ឬ កាន់កាប់ទ្រព្យសម្បត្តិរបស់អ្នកទទួលអាជ្ញាប័ណ្ណ ។

ឈ- ក្នុងអំឡុងឆ្នាំទី១ នៃរយៈពេលអាជ្ញាប័ណ្ណនេះ អ្នកទទួលអាជ្ញាប័ណ្ណមិនបានជំរុញ និងលក់សន្លឹកឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា ។

ញ- អ្នកទទួលអាជ្ញាប័ណ្ណបានប្រព្រឹត្តិបទឧក្រិដ្ឋ ឬប្រព្រឹត្តិអំពើមិនស្របច្បាប់ណាមួយ ដែលក្រសួងយល់ថាជាទង្វើមិនសមស្របជាអ្នកកាន់អាជ្ញាប័ណ្ណ ។ បន្ទាប់ពីការលុបអាជ្ញាប័ណ្ណ អ្នកទទួលអាជ្ញាប័ណ្ណត្រូវបញ្ឈប់ជាបន្ទាន់នូវការលក់សន្លឹកឆ្នោតលើទីផ្សារ និង សកម្មភាពធ្វើអាជីវកម្មឆ្នោតទៀត ហើយមិនត្រូវថាខ្លួនជាអ្នកកាន់អាជ្ញាប័ណ្ណឆ្នោតដែលបានចេញដោយក្រសួងឡើយ ។

## ប្រការ ១៤ : សេចក្តីជូនដំណឹង

សេចក្តីជូនដំណឹងណាមួយដែលបានចេញដោយក្រសួង និងចេញដោយអ្នកទទួលអាជ្ញាប័ណ្ណត្រូវ ធ្វើឡើងជាលាយលក្ខណ៍អក្សរទៅកាន់អ្នកតំណាងស្របច្បាប់នៃភាគីពាក់ព័ន្ធដោយ : (១) ហុចជូនដល់ដៃ (២) ឬតាមប្រៃសណីយ៍ (៣) ឬទូរសារ ។ សេចក្តីជូនដំណឹងទាំងនេះ ចាត់ទុកជាបានទទួល : (១) ដោយមានបញ្ជាក់ពេលវេលានៃការទទួល ប្រសិនបើផ្តល់អោយផ្ទាល់ដៃ (២) ចុះហត្ថលេខាទទួលបើជាអនុសិដ្ឋ (៣) ឬនៅពេលដែលបានទទួលច្បាប់ចម្លងនៃសេចក្តីជូនដំណឹងនេះតាមទូរសារដោយសុវត្ថិភាពប្រសិនបើផ្ញើតាមទូរសារ ។

**ប្រការ ១៥ : ច្បាប់គ្រប់គ្រង-ភាសា**

អាជ្ញាប័ណ្ណត្រូវបានគ្រប់គ្រង និងកំណត់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ អាជ្ញាប័ណ្ណត្រូវបានធ្វើឡើងជាពីរភាសា : ខ្មែរ និងអង់គ្លេស ។ អត្ថបទភាសាខ្មែរជាអត្ថបទផ្លូវការនៃអាជ្ញាប័ណ្ណ ។

អាជ្ញាប័ណ្ណចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០២

ទេសរដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ខ្ញុំបាទ BENJAMIN JOSEPH PERRY ជានាយក ក្រុមហ៊ុនសាជីវកម្ម Golden Win Win (Cambodia) Inc សូមសន្យា នឹងគោរពទូរាល់ខ្លឹមសារ ដូចមានចែងក្នុងលក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណ និងបទបញ្ញត្តិផ្សេងៗ ទៀតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្នុងករណីដែលខ្ញុំមិនគោរពតាមនេះ ខ្ញុំបាទ សូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន ។

ភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ ២០០២

ហត្ថលេខា